00170819

Declassified to Public
06 September 2012

ឯកសារ/N°: A78

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 03 / 2008
ម៉ោង (Time/Heure): 15:00 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អ.វ.ត.ក.**

**យោង: VU-2008-005**

**27/02/2008**

**កម្មវត្ថុ: ពាក្យស្នើសុំឱ្យទទួលស្គាល់សហមេធាវីអន្តរជាតិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង, ជុំ ម៉ី និង ឈិន ណារី**

ឯកសារថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 14 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

លោកសហចៅក្រមស៊ើបអង្កេតជាទីគោរព,

អង្គភាពជនរងគ្រោះ នៅក្នុងសមត្ថកិច្ចជាចំណុចទាក់ទងកណ្តាលរវាង អ.វ.ត.ក. និង ជនរងគ្រោះនិងតំណាងផ្លូវច្បាប់របស់ពួកគេ បានទទួលលិខិតចាត់តាំងមេធាវីពី លោក ប៊ូ ម៉េង, លោក ជុំ ម៉ី និង លោកស្រី ឈិន ណារី, ដែលជាភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក.- ក.ស.ច.ស. (ប៊ូ ម៉េង, ជុំ ម៉ី និង ឈិន ណារី) និងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក.-ក.ស.ច.ស. (ជុំ ម៉ី និង ឈិន ណារី)។ ក្នុងឱកាសនេះយើងសូមផ្ញើលិខិតនោះជូនការិយាល័យលោកសហចៅក្រម។

ក្នុងលិខិតរបស់គាត់ លោក ប៊ូ ម៉េង, លោក ជុំ ម៉ី និង លោកស្រី ឈិន ណារី បានចាត់តាំង លោកស្រីមេធាវី Silke Studzinsky ជាមេធាវីអន្តរជាតិតំណាងឱ្យពួកគាត់ក្នុងគ្រប់នីតិវិធី នៅចំពោះមុខ អ.វ.ត.ក.។ លោកស្រីមេធាវី Silke Studzinsky បានផ្ញើពាក្យសុំចុះឈ្មោះក្នុងបញ្ជីមេធាវីដែលមានគោលបំណងចង់តំណាងឱ្យភាគីរដ្ឋប្បវេណី។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានទទួលពាក្យសុំនោះហើយ និងកំពុងកំណត់កាលបរិច្ឆេទសំរាប់ការធ្វើពិធីសច្ចាប្រណិធាន ដែលនឹងកើតឡើងក្នុងសប្តាហ៍នេះឬសប្តាហ៍ក្រោយ។

អាស្រ័យហេតុនេះ អង្គភាពជនរងគ្រោះសូមផ្ញើជូននូវសំណើពី លោក ប៊ូ ម៉េង, លោក ជុំ ម៉ី និង លោកស្រី ឈិន ណារី ដើម្បីឱ្យលោកសហចៅក្រមពិនិត្យពិចារណាទទួលស្គាល់ការជ្រើសរើសតំណាងផ្លូវច្បាប់របស់គេ។

Translated from 00165473-00165473

ការ/ស A 78

សូមអរគុណសំរាប់ការយកចិត្តទុកដាក់ក្នុងរឿងនេះ។

ដោយការរាប់អានខ្ពង់ខ្ពស់

គាត បូផល

ប្រធាន

អង្គភាពជនរងគ្រោះ



ECCC, National Road 4, Ang Snuol, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh